ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# សុន្ទរកថា

## ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ
## និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
## តំណាងដ៏ខ្ពង់ខ្ពស់
## សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីបើក ទិវាជាតិអន្តរសាសនា ដើម្បីប្រឆាំងការជួញដូរមនុស្ស លើកទី៩ ឆ្នាំ២០២៥
ក្រោមប្រធានបទ «សុខដុមនីយកម្មសាសនានៅកម្ពុជា ជាសក្តានុពលក្នុងការប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់
នាសម័យបច្ចេកវិទ្យា»
ថ្ងៃពុធ ១១រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ត្រូវនឹងថ្ងៃទី ២០ ខែសីហា ឆ្នាំ២០២៥
នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិជ្រោយចង្វារ (OCIC)

- សូមក្រាបថ្វាយបង្គំ សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ សម្តេចព្រះសង្ឃនាយក សម្តេចព្រះសង្ឃនាយករង ព្រះរាជាគណៈ ព្រះមន្ត្រីសង្ឃ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ !
- សម្តេច ឯកឧត្តម លោកជំទាវ **សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល !**
- ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ឯកឧត្តមនាយឧត្តមសេនីយ៍ អគ្គស្នងការ អនុប្រធាន សមាជិក សមាជិកា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត កុងស៊ុល និងតំណាងស្ថានបេសកកម្មនានាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា !
- ប្រធាន និងតំណាង អង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការសង្គមស៊ីវិល !
- ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត !
- តំណាង**គ្រប់និកាយសាសនា** និងបងប្អូនជនរួមជាតិទាំងអស់ ជាទីស្រឡាញ់រាប់អាន !

ថ្ងៃនេះ ក្នុងនាម **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមខ្ញុំព្រះករុណាខ្ញុំបាទផ្ទាល់ និងភរិយា មានសេចក្តីរីករាយ សោមនស្សរីករាយក្រៃលែង ដែលបានមកចូលរួមជាអធិបតី ក្នុងពិធីដ៏មហានក្ខត្តឫក្សនៃទិវាជាតិអន្តរសាសនាលើកទី៩ ដែលបានរៀបចំឡើងដោយ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** ក្រោមប្រធានបទ «**សុខដុមនីយកម្មសាសនានៅកម្ពុជា ជាសក្តានុពល**

**ក្នុងការប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ នាសម័យបច្ចេកវិទ្យា»** ។ នេះជាការជួបជុំដ៏មានអត្ថន័យ ដោយបានបង្ហាញអំពីស្មារតី សាមគ្គីភាព ឯកភាព និងសុខដុមនីយកម្ម នៃគ្រប់ជំនឿសាសនា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាមូលដ្ឋានគ្រឹះនៃសុខសន្តិភាពរបស់សង្គមជាតិ ធ្វើឱ្យមនុស្សទាំងឡាយទទួលបាននូវសេចក្តីសុខផ្លូវកាយ ផ្លូវចិត្ត ចាកទុក្ខភ័យ គ្រោះចង្រៃ និងវិនាសកម្មទាំងឡាយ ដែលបង្កឡើងដោយមនុស្សក្តី ឬ ដោយធម្មជាតិក្តី។ អាស្រ័យដោយការដឹកនាំនៃគ្រប់និកាយសាសនា ក្នុងព្រះរាជាណាចក្រកម្ពុជា បានល្អប្រសើរដែលនៅទីនេះមានតំណាងព្រះពុទ្ធសាសនាទាំងពីរនិកាយ តំណាងឥស្លាមសាសនាកម្ពុជាពីរនិកាយ និងតំណាងគ្រីស្ទសាសនាបីនិកាយ ជានិមិត្តរូបស្រាប់ បានបង្ហាញឱ្យឃើញអំពីភាព សុខុដុមរមនា និងរួមសហការគ្នា ក្នុងការលុបបំបាត់ជាបណ្តើរៗ នូវអំពើអសីលធម៌ដែលកើតមានក្នុងសង្គម និងបានបង្ការទប់ស្កាត់ ក៏ដូចជាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ ដែលបាននិងកំពុងបំផ្លាញសេចក្តីថ្លៃថ្នូរក្នុងភាពជាមនុស្ស និងបង្កជាគ្រោះថ្នាក់ដល់មនុស្សគ្រប់វ័យ គ្រប់ស្ថានភាព គ្រប់ពណ៌សម្បុរគ្រប់ វណ្ណៈសង្គម ដោយឥតរើសមុខ។

ចាប់តាំងពីឆ្នាំ២០១៧ មក ព្រះរាជាណាចក្រកម្ពុជាយើង តែងប្រារព្ធពិធីអន្តរសាសនាប្រឆាំងអំពើជួញដូរមនុស្ស យ៉ាងអធឹកអធម ក្រោមការគាំទ្រប្រកបដោយឆន្ទៈដ៏មុះមុត របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាប្រធានព្រឹទ្ធសភា តាំងពីលោកនៅជា ប្រមុខរាជរដ្ឋាភិបាលកម្ពុជា និងក្រោមការដឹកនាំផ្ទាល់របស់ **សម្តេចក្រឡាហោម ស ខេង** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ **អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**។ ជាសក្ខីភាពជាក់ស្តែងនៅឆ្នាំ២០២១ ក្នុងនីតិកាលទី៦ នៃរដ្ឋសភា អំឡុងពេលនៃការឆ្លងរីករាលដាលយ៉ាងកាចសាហាវនៃជំងឺកូវីដ-១៩ ទោះបីពុំមានកម្មវិធីជួបជុំក្នុងទ្រង់ទ្រាយធំដូចនេះក៏ដោយក៏ **សម្តេចតេជោ ហ៊ុន សែន អតីតប្រមុខរាជរដ្ឋាភិបាលកម្ពុជា** បានធ្វើសេចក្តីថ្លែងជាសារសម្លេង និងវីដេអូដើម្បីបើកកម្មវិធីអបអរសាទរវេទិកាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស ដោយមានការទូងស្គរ វាយជួងនៅតាមអារាមសាសនាទូទាំងប្រទេស ដើម្បីរំលឹកដល់ជនរួមជាតិ អំពីសារសំខាន់ការប្រារព្ធពិធីអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស និងបួងសួងអធិដ្ឋាន ដោយធ្វើការប្តេជ្ញាចិត្តរួមគ្នា ក្នុងការលុបបំបាត់អំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើប ក្រោមប្រធានបទ **«សូមពិភពលោករួចផុតពីកូវីដ-១៩ និងអំពើជួញដូរមនុស្ស»**។ នៅ**ឆ្នាំ ២០២២** សម្តេចប្រមុខរាជរដ្ឋាភិបាល បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីមិទ្ទិញ និងបានប្រកាស**កំណត់យកថ្ងៃទី ២០ ខែសីហា រៀងរាល់ឆ្នាំ** ជាថ្ងៃប្រារព្ធពិធី **ទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស**។

នៅក្នុងនីតិកាលទី៧ នៃរាជរដ្ឋាភិបាល កម្មវិធីនេះបានបន្តប្រារព្ធធ្វើឡើង តាមរយៈការរៀបចំជាមិទ្ទិញថ្នាក់ជាតិ ដោយមានការយាង និងនិមន្តយ៉ាងច្រើនកុះកររបស់សម្តេចព្រះសង្ឃនាយក ព្រះសង្ឃនាយករង ព្រះរាជាគណៈព្រះមន្ត្រីសង្ឃ និងព្រះថេរានុត្ថេរៈ តំណាងព្រះពុទ្ធសាសនា ទាំងពីរនិកាយ និងការអញ្ជើញចូលរួមពីមេដឹកនាំ និងសាសនិកនិកាយទាំងពីរ នៃឥស្លាមសាសនា និងបីនិកាយក្នុងគ្រីស្ទសាសនា ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំក្នុងស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ តុលាការ មន្ត្រីរាជការ ពីគ្រប់ក្រសួងស្ថាប័ន មន្ទីរអង្គភាព កងកម្លាំងប្រដាប់អាវុធ គ្រប់ប្រភេទ ថ្នាក់ដឹកនាំរាជធានី-ខេត្ត ខណ្ឌ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ សង្គមស៊ីវិល វិស័យឯកជន សិស្សនិស្សិត យ៉ាងច្រើនកុះករ ដែលជាការឆ្លុះបញ្ចាំងនូវស្មារតីរួបរួមគ្នាជាធ្លុងមួយក្នុងសង្គមកម្ពុជា។ រាជរដ្ឋាភិបាលនីតិកាលទី៧ ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បាននឹងកំពុងបន្តវេន ដឹកនាំប្រទេសជាតិ យ៉ាងស្វាហាប់ឆ្ពោះទៅកាន់ **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០** តាម **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** និងបន្តប្តេជ្ញាចិត្តប្រយុទ្ធប្រឆាំងដាច់ខាតអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងបទល្មើសឧក្រិដ្ឋដទៃទៀត ដែលជាឧបសគ្គរាំង ដល់ដំណើរការអភិវឌ្ឍន៍ជាតិគ្រប់វិស័យ ។

ក្នុងនាម ***សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា*** និងក្នុងនាមខ្ញុំព្រះករុណាខ្ញុំបាទផ្ទាល់ ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ ប្រកបដោយមោទនភាព ចំពោះភាពសុខដុមរមនានៃគ្រប់ជំនឿសាសនានៅកម្ពុជា ដែលតែងតែរួមរស់ជាមួយគ្នាដោយសុខសាន្ត មានសាមគ្គីភាព និងកិច្ចសហការល្អគាំទ្រគ្នាទៅវិញទៅមកដោយភាពទន់ភ្លន់ មិនមានទំនាស់ មិនប្រទូស្តរ៉ាយគ្នា និងមិនដែលបង្កឱ្យមានការបែកបាក់ក្នុងសង្គមជាតិឡើយ។ មិនតែប៉ុណ្ណោះ សាសនាទាំងឡាយនៅកម្ពុជា បានឯកភាពរួមគ្នាដោះស្រាយបញ្ហាប្រឈមទាំងឡាយ ក្នុងសង្គម រួមទាំងអំពើជួញដូរមនុស្ស តាមរយៈការបង្ការទប់ស្កាត់ដោយការអប់រំបែបសីលធម៌។

យើងនៅចាំមិនភ្លេចទេថា ក្នុងរបបប្រល័យពូជសាសន៍ នាអំឡុងទសវត្សរ៍ឆ្នាំ៧០ ជំនឿសាសនានៅកម្ពុជាត្រូវបានបំផ្លាញដល់ឫសគល់។ វត្តអារាម និងវិហារសាសនាទាំងឡាយ ត្រូវបានប្រើប្រាស់ជាកន្លែងធ្វើទារុណកម្ម ឬកន្លែងពិឃាដមនុស្ស ជាឃ្លាំងអាវុធ ឃ្លាំងសម្ភារៈ គ្មានព្រះសង្ឃ ឬបព្វជិតសាសនាណាហ៊ានទាមទារសិទ្ធិ ឬហ៊ានសម្តែងនូវឆន្ទៈ ឬធ្វើការគោរពប្រណិបត្តិព្រះជាម្ចាស់ដោយចំហរបានឡើយ។ កុំថាឡើយតែអ្នកដទៃ បើសូម្បីតែបងប្អូន ឪពុកម្តាយ របស់ខ្លួន ក៏ហ៊ានធ្វើទារុណកម្ម ឬសម្លាប់យ៉ាងព្រៃផ្សៃដែរ។ ទង្វើដ៏អកុសលទាំងនេះ កើតចេញពីទស្សនៈ និងឥរិយាបទអសីលធម៌ ដែលមនុស្សទាំងនោះហ៊ានប្រព្រឹត្តអាក្រក់លើមនុស្សដូចគ្នា និងសាហាវឃោរឃៅ ជាងសត្វតិរិច្ឆានទៅទៀត។ តែក្រោយពីមានការលះបង់ និងបានធ្វើពលិកម្មគ្រប់បែបយ៉ាងរបស់វីរជនស្នេហាជាតិជាច្រើនរូប ដែលហ៊ានលះបង់ជីវិត ប្តូរយកសេចក្តីសុខ និងសន្តិភាពជូនជាតិ និងប្រជាជនកម្ពុជា ក្នុងអំឡុងឆ្នាំ១៩៧៩ បានធ្វើឱ្យកម្ពុជាមានសន្តិសុខនិងសុវត្ថិភាពជាបណ្តើរៗ រហូតទទួលបានសន្តិភាពពេញបរិបូរណ៍ក្រោម **នយោបាយ ឈ្នះ-ឈ្នះ** របស់ ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*** ក្នុងឆ្នាំ១៩៩៨។ ក្នុងកាលៈទេសៈនោះ ប្រទេសជាតិ មានការបង្រួបបង្រួមរវាងមនុស្សដែលមាននិន្នាការខុសគ្នា ឱ្យអាចរស់នៅជាមួយគ្នាក្រោមដំបូលរដ្ឋធម្មនុញ្ញតែមួយ រដ្ឋាភិបាលតែមួយ ជាតិតែមួយ ព្រះមហាក្សត្រតែមួយ គ្មានតំបន់បែងចែកអប្បគមន៍ និងការបែកបាក់ជាតិឡើយ។ ជំនឿសាសនាទាំងឡាយ ចាប់ផ្តើមរស់ឡើងវិញ និងមានភាពសុខុមរមនាជាមួយគ្នា ដែលធ្វើឱ្យមាតុភូមិកម្ពុជា ក្លាយជាកន្លែងមានសុវត្ថិភាព សន្តិភាពផ្លូវកាយ ផ្លូវចិត្ត ចេះគោរពឱ្យតម្លៃមនុស្សដូចគ្នាដោយឥតមានរើសអើង ពូជសាសន៍ ពណ៌សម្បុរ ជំនឿ សាសនា អ្វីឡើយ។ ប្រជាជនកម្ពុជាស្រឡាញ់សន្តិភាព យល់ពីសារសំខាន់នៃសន្តិភាព និងខិតខំថែរក្សាសន្តិភាពមិនឱ្យបាត់បង់។ រហូតមកដល់ពេលបច្ចុប្បន្ននេះ ព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា ប្រជាជនកម្ពុជា មានភាពធន់ ទៅនឹងគ្រប់ស្ថានភាពវិបត្តិតូចធំដែលបាន និងកំពុងប្រឈម រួមទាំងគ្រោះធម្មជាតិ ភាពតានតឹងនៃ ភូមិសាស្ត្រនយោបាយ ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសកល ការប្រកួតប្រជែងក្នុងវិស័យពាណិជ្ជកម្ម វិស័យបច្ចេកវិទ្យា រហូតដល់ការផ្ទុះឡើងនូវសង្គ្រាមឈ្លានពានពីអមិត្ត តែកម្ពុជានៅតែតស៊ូ... ដោយប្រកាន់ជំហរដោះស្រាយដោយសន្តិវិធី បញ្ចៀសសង្គ្រាមបង្ហូរ

ឈាមប្រឈមមុខដាក់គ្នាដែលនាំមកនូវគ្រោះមហន្តរាយបំផ្លាញជីវិតមនុស្ស និងធនធានធម្មជាតិ និងសម្បត្តិវប្បធម៌ដ៏មានតម្លៃ មិនអាចប៉ាន់ស្មានបាន។ រាជរដ្ឋាភិបាលកម្ពុជា បានព្យាយាមអស់ពីលទ្ធភាព បង្កើតឱ្យបាននូវសុវត្ថិភាព សន្តិសុខសង្គម ដើម្បីធ្វើឱ្យសម្រេចនូវសមិទ្ធិផល និងបរិវត្តកម្មសំខាន់ៗ ដែលបានគ្រោងទុកក្នុងផែន ការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់ខ្លួន និង កសាងនូវមិត្តភាព កិច្ចសហប្រតិបត្តិការដើម្បីការអភិវឌ្ឍន៍ជាមួយប្រទេសតូចធំលើសកលលោក។

ឆ្នាំ២០២៥នេះ មានព្រឹត្តិការណ៍សំខាន់ៗមួយចំនួនដែលបានកើតឡើង និងធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព ប្រជាពលរដ្ឋ និងប្រទេសជាតិ នោះគឺសង្គ្រាមប្រដាប់អាវុធ តាមខ្សែបន្ទាត់ព្រំដែន កម្ពុជា ថៃ ដែលបណ្តាលមកពីការរំលោភឈ្លានពា។ កម្ពុជា តែងសង្ឃឹមថា យើងមានព្រំដែនមួយ ដែលមានសុវត្ថិភាព មានកិច្ចសហការល្អ និងមានការអភិវឌ្ឍន៍រីកចម្រើន រួមគ្នាជាមួយប្រទេសជិតខាង។ កម្ពុជា តែងរក្សាខ្ជាប់ នូវស្មារតី ភាតរភាព និងព្យាយាមដោះស្រាយបញ្ហាដោយសន្តិវិធី និងរក្សានូវទំនាក់ទំនងល្អជាមួយគ្នាគ្រប់វិស័យដើម្បីភាពសុខសាន្ត លំហូរសេដ្ឋកិច្ចទៅវិញទៅមក។ ជាអកុសល ដែល ក្នុងឆ្នាំ២០២៥នេះ ស្ថានភាពបានប្រែប្រួលផ្លាស់ប្តូរពីការប្រាស្រ័យទាក់ទង ដែលធ្លាប់តែល្អប្រសើរ ទៅជាល្អក់កករ និងឈានដល់ការបាញ់សម្លាប់យុទ្ធជនខ្មែរ ដោយមិនដឹងខ្លួន និងមានការរំលោភឈ្លានពាន កាន់តែធ្ងន់ធ្ងរ រហូតដល់ប្រើអាវុធធុនធ្ងន់ ការប្រើយន្តហោះ F 16 ទម្លាក់គ្រាប់បែក ទម្ងន់ រាប់តោន បំផ្លាញវត្តអារាម ប្រាសាទព្រះវិហារដែលជាបិតិកភ័ណ្ឌពិភពលោក ដណ្តើមកាន់កាប់ប្រាសាទ និងរាយបន្លាលួស វាតយកទីតាំងព្រំដែនដែលជាភូមិឋានប្រជាពលរដ្ឋកម្ពុជាបាននិងកំពុងរស់នៅ តាំងពីរាប់ជំនាន់មកហើយ មិនតែប៉ុណ្ណោះ កងទ័ពថៃឈ្លានពាន បានប្រើផ្សែងពុល តែបង្កផលប៉ះពាល់ដល់អាយុជីវិត និងសុខភាព កងទ័ពដែលកំពុងឈរជើងការពារទឹកដី និងប្រជាពលរដ្ឋយ៉ាងធ្ងន់ធ្ងរ ធ្វើឱ្យប្រជាពលរដ្ឋត្រូវភៀសខ្លួនចាកចេញពីភូមិឋាន ផ្ទះសម្បែង មករស់នៅក្នុងជំរំភៀសសឹក ដ៏លំបាកយ៉ាប់យ៉ឺន។ មិនតែប៉ុណ្ណោះ ពលករ និងប្រជាជនកម្ពុជា ដែលបាន និងកំពុងស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃប្រមាណ ១លាន បីសែននាក់ និងប្រជាពលរដ្ឋមួយចំនួន បានទទួលរងនូវការធ្វើទុកបុកម្នេញ ដោយការប្រមាថ កេងប្រវ័ញ្ច ប្រើអំពើហិង្សា បណ្តេញចេញ យ៉ាងឈឺចាប់ ដែលមិនអាចទទួលយកបាន។ ពលករ បាននាំគ្នាវិលត្រឡប់មកកម្ពុជាវិញ យ៉ាងគំហុក ដែលក្នុងរយៈពេលត្រឹមតែ ជាង៣០ថ្ងៃចុងក្រោយនេះ មានប្រជាពលរដ្ឋវិលត្រឡប់មកវិញ រហូតដល់ទៅជាង ៩០ម៉ឺននាក់ ។ នេះគឺជាបន្ទុក ថ្មីមួយទៀត ដែលរាជរដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវតែទទួលដោះស្រាយ និងថែទាំ គាំពារ ប្រជាពលរដ្ឋខ្លួន ឱ្យបានល្អ និងបានផ្តល់ឱកាសការងារ ការរៀនសូត្រជំនាញវិជ្ជាជីវៈ និងមុខរបរអាជីវកម្ម ផ្សេងៗ ដើម្បីដោះស្រាយជីវភាពនៅក្នុងប្រទេស បានយ៉ាងល្អប្រសើរ ។

ទង្វើបែបនេះ គឺជាអំពើអសីលធម៌មួយយ៉ាងធ្ងន់ធ្ងរ ដែលបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខជាតិនៃប្រទេសទាំងពីរ និងក្នុងតំបន់ ដែលធ្លាប់តែមានចំណងមិត្តភាពល្អប្រសើរ។ កម្ពុជា នៅតែប្រកាន់ជំហរដាច់ខាត និងព្យាយាមដោះស្រាយ ដោយសន្តិវិធី តាមការចរចា និងតាមផ្លូវច្បាប់ ដើម្បីបន្ថយកំដៅនៃជម្លោះប្រដាប់អាវុធ និងគោរពនូវបទឈប់បាញ់យ៉ាងខ្ជាប់ខ្ជួន ក្នុងគោលដៅរក្សាឱ្យបាន នូវសន្តិសុខសណ្តាប់ធ្នាប់ក្នុងតំបន់ និងអាយុជីវិតប្រជាពលរដ្ឋទាំងសងខាង។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមឆ្លៀតឱកាសនេះ ថ្លែងអំណរគុណ ថ្នាក់ដឹកនាំនិងប្រជាជននៃបណ្តាប្រទេស លើសកលលោក ដែលនៅតែឈរខាងសច្ចធម៌ ស្រឡាញ់សន្តិភាព និងទទួលស្គាល់ការពិត ហើយគាំទ្រកម្ពុជា ឱ្យដោះស្រាយបញ្ហាតាមផ្លូវច្បាប់ដើម្បីបញ្ចប់ជម្លោះព្រំដែន និងសូមអរគុណ ជាពិសេស លោក **Donald J. Trump** ប្រធានាធិបតី សហរដ្ឋអាម៉េរិក ដែលបានដាក់ចេញនូវគោលការណ៍សន្តិភាពដ៏មានឥទ្ធិពល គាំទ្របទឈប់បាញ់ ដែលនាំមកនូវការដោះស្រាយដោយសន្តិវិធី និងសន្តិភាពសម្រាប់ប្រជាជន និងប្រទេសទាំងសងខាង ដែលនេះជាបំណងប្រាថ្នារបស់ប្រជាជនកម្ពុជាគ្រប់រូប។ សូមថ្លែងអំណរគុណ ឯកឧត្តម **Anwar Ibrahim** នាយករដ្ឋមន្ត្រី ប្រទេសម៉ាឡេស៊ី និងជាប្រធានប្តូរវេនអាស៊ាន ដែលបានជួយសម្របសម្រួល កិច្ចប្រជុំ **GBC** រវាង កម្ពុជា ថៃ និងឈានដល់ការចុះកិច្ចព្រមព្រៀងលើបទឈប់បាញ់ និងសូមអរគុណចំពោះ សាធារណរដ្ឋប្រជាមានិតចិន និងប្រទេសឥណ្ឌូណេស៊ី និងបណ្តាមិត្តក្នុងសហគមន៍អាស៊ាន និងបណ្តាប្រទេសជាមិត្ត ដែលជានិច្ចជាកាលឈរលើភាពត្រឹមត្រូវ កិច្ចសហការល្អ និងគាំទ្រដល់ដំណោះស្រាយ តាមផ្លូវចរចាស្វែងរកសន្តិភាព។

- ***សម្តេច ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ***
- ***សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី យុវជន យុវនារី ភ្ញៀវជាតិ អន្តរជាតិ និងបងប្អូនជនរួមជាតិ ជាទីគោរព រាប់អាន***

ព្រឹត្តការណ៍ទាំងឡាយ ដែលបានកើតឡើងចំពោះកម្ពុជា នៅក្នុងតំបន់ និងនៅក្នុងពិភពលោក បានធ្វើឱ្យយើងទាំងអស់គ្នា អាចយល់បានថា ហេតុដែលនាំឱ្យបទល្មើសជួញដូរមនុស្ស និងឧក្រិដ្ឋកម្មទាំងឡាយ ក្នុងតំបន់ និងនៅលើពិភពលោក មិនទាន់បានថមថយ និងមិនអាចលុបបំបាត់បាន មិនមែនដោយសារតែរដ្ឋាភិបាលនៃបណ្តាប្រទេសទាំងឡាយ ព្រងើយកន្តើយ មិនខិតខំប្រឹងប្រែងបង្ក្រាប និងលុបបំបាត់នោះទេ ប៉ុន្តែមូលហេតុសំខាន់ គឺមកពី នៅតែមានមនុស្សដែលខ្វះសីលធម៌ អមនុស្សធម៌ មិនខ្វាយខ្វល់អំពីគ្រោះមហន្តរាយរបស់អ្នកដទៃ ដែលនៅតែប្រព្រឹត្តបទល្មើសទាំងអស់នោះ តាមគ្រប់មធ្យោបាយមិនឈប់ឈរ។ ទោះបីជាមានច្បាប់ជាតិ និងអន្តរជាតិជាច្រើនសម្រាប់អនុវត្ត តែជនល្មើសមិនកោតញញើតឡើយ ហើយបានរិះរកកលល្បិច គួបផ្សំនឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាដែលកាន់តែទំនើប ដើម្បីសម្រេចមហិច្ឆិតារបស់ខ្លួន គឺការទាញយកផលចំណេញមហាសាលពីអំពើជួញដូរ និងកេងប្រវ័ញ្ចលើមនុស្សគ្រប់រូបភាព។ ការពិតបច្ចេកវិទ្យា ត្រូវបានបង្កើតឡើងដើម្បីបម្រើ សេចក្តីត្រូវការរបស់មនុស្ស ក្នុងជីវិតរស់នៅប្រចាំថ្ងៃកាន់តែងាយស្រួល។ ប្រទេសនានា លើសកលលោក តែងបង្កើនការប្រើប្រាស់ បច្ចេកវិទ្យា សម្រាប់ការអភិវឌ្ឍន៍គ្រប់វិស័យ។ ដោយឡែក ព្រះរាជាណាចក្រកម្ពុជា ក៏បាននិងកំពុងបោះជំហានទៅមុខយ៉ាងមុតមាំក្នុងការជំរុញវឌ្ឍនភាពលើគ្រប់វិស័យ ដោយកំណត់ថា វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាវិស័យស្នូល សម្រាប់ ក្រសួង ស្ថាប័ន ក្នុងការបង្កើនផលិតភាពតាមវិស័យរបស់ខ្លួន ឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍ជាតិ។

ផ្ទុយទៅវិញ ឧក្រិដ្ឋជន ដែលជាមនុស្សអសីលធម៌ បានប្រើប្រាស់វិទ្យាសាស្ត្របច្ចេកវិទ្យាទាំងនោះ ដើម្បីជាមធ្យោបាយក្នុងការបោកបញ្ឆោត កេងប្រវ័ញ្ច ទាញយកផលប្រយោជន៍មហាសាលពីមនុស្សទាំងឡាយ ដោយឥតរើសមុខ និងសម្រាប់បង្កើតជាអាវុធបំផ្លាញគ្នាទៅវិញទៅមក យ៉ាងសាហាវឃោរឃៅ ។

ហេតុនេះ ការអប់រំសីលធម៌ក្នុងការរស់នៅដល់មនុស្សទូទៅ គឺជាតម្រូវការចាំបាច់ និងមានសារសំខាន់បំផុត ក្នុងការធ្វើឲ្យមនុស្សទាំងឡាយ លើពិភពលោកនេះ ទទួលបាននូវសេចក្ដីសុខ និងលះបង់អំពើជាអកុសល ឬ បទល្មើសទាំងឡាយ ដែលបង្កភាពរងគ្រោះដល់បុគ្គល និងសង្គមមនុស្សយ៉ាងធ្ងន់ធ្ងរ។ លុះត្រាតែមនុស្សទាំងឡាយ កុំបៀតបៀនគ្នា ចេះគោរពឱ្យតម្លៃគ្នា និងចេះចែករំលែកសេចក្ដីសុខឱ្យគ្នាទៅវិញទៅមក ទើបអាចកាត់បន្ថយទង្វើអសីលធម៌ទៅលើមនុស្សផងគ្នាបាន។ ក្នុងន័យនេះ ក្រៅពីច្បាប់ជាតិ អន្តរជាតិដែលដាក់ទោសទណ្ឌលើជនប្រព្រឹត្តបទល្មើស យើងមានយន្តការសម្រាប់ជំរុញការអនុវត្ត ក៏ដូចជាវិធានការបំពេញបន្ថែមជាច្រើនទៀត តែយើងនៅតែត្រូវការកិច្ចសហប្រតិបត្តិការនៅផ្ទៃក្នុងជាតិ និងជាអន្តរជាតិ ប្រកបដោយស្មារតីសាមគ្គីសហការ និងក្រមសីលធម៌វិជ្ជាជីវៈ ដើម្បីជាបន្សាបឥទ្ធិពលនៃបទល្មើសជួញដូរមនុស្ស និងឧក្រិដ្ឋកម្មពាក់ព័ន្ធទាំងឡាយ តាមយុទ្ធសាស្ត្រ បង្ការទប់ស្កាត់ បង្ក្រាប ផ្ដន្ទាទោសជនល្មើស ផ្ដល់កិច្ចការពារជនរងគ្រោះឱ្យបានកាន់តែល្អប្រសើរ។

កន្លងមក ប្រជាជនកម្ពុជាជាច្រើន បានរងគ្រោះដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្សេងៗ ក្នុងកំឡុងពេលនៃការធ្វើទេសន្តរប្រវេសន៍ស្វែងរកការងារនៅក្រៅប្រទេស ជាពិសេសក្នុងអំឡុងពេលផុតសុពលភាពច្បាប់ ឬមិនមានឯកសារច្បាប់ជាដើម ។ ក្នុងឆមាសទី២ ឆ្នាំ២០២៥ នេះ ព្រឹត្តិការណ៍ ដែលមិនមានការព្រាងទុកបានកើតឡើង គឺជម្លោះប្រដាប់អាវុធ ដែលបង្ករឡើងដោយការឈ្លានពានទឹកដី ពីប្រទេសថៃលើអធិបតេយ្យភាពកម្ពុជា និងការធ្វើទុកបុកម្នេញ ប្រមាថ មាក់ងាយ ប្រើអំពើហិង្សា និងកេងប្រវ័ញ្ច លើពលករកម្ពុជា ដែលមានប្រមាណ មួយលាន ២សែននាក់ បាន និងកំពុងធ្វើការ ក្នុងប្រទេសថៃ ដែលនាំឲ្យពលករ មិនអាចស៊ូទ្រាំរស់នៅទីនោះបានបន្តទៀត និងនាំគ្នាត្រឡប់មកមាតុភូមិកម្ពុជាវិញ យ៉ាងគំហុក ។ ពលករកម្ពុជា ប្រមាណ ១លាននាក់រួចហើយ ដែលបានវិលត្រឡប់មកដល់កម្ពុជាវិញ និងត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ទទួលស្វាគមន៍ ផ្ដល់ឱកាសការងារ មុខរបរ និងសេវាគាំទ្រនានា ដើម្បីស្ដារស្ថានភាពដែលកំពុងជួបការលំបាក ខ្វះខាត និងភ័យខ្លាច។ ទោះបីកម្ពុជា កំពុងប្រឈមនឹងការលំបាក ទាំងការប្រឈមមុខនឹងការរំលោភឈ្លានពាន ការបិទខ្ទប់សេដ្ឋកិច្ច និងដំណោះស្រាយបញ្ហាសង្គម រួមទាំងបញ្ហាជនភៀសសឹកពីព្រំដែនជម្លោះរវាងកម្ពុជា ថៃយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវពង្រឹងការទទួលខុសត្រូវ ក្នុងការផ្ដល់នូវសុវត្ថិភាពដល់ប្រជាជនទាំងអស់ ផ្ដល់លទ្ធភាព និងជម្រើសក្នុងការរស់នៅដែលល្អប្រសើរ ក្នុងប្រទេសរបស់ខ្លួន។ ចំណែកការបង្ក្រាបបទល្មើស ដែលកើតមាន នៅកម្ពុជា រួមទាំង បទល្មើស ឆបោកតាមអនឡាញ ក៏កម្ពុជាមិនបានព្រងើយកន្តើយដែរ ហើយ ខិតខំបោសសម្អាតឱ្យបានធាប់រហ័ស ដើម្បីទុកលំហរសុវត្ថិភាព សន្តិសុខ សម្រាប់ប្រជាពលរដ្ឋទូទៅ រួមទាំងជនបរទេស ដែលបាន និងកំពុង មានវត្តមានលើទឹកដីកម្ពុជា ផងដែរ ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្នុងនាម **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងក្នុងនាមទូលបង្គំ ខ្ញុំព្រះករុណាខ្ញុំផ្ទាល់ សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះស្មារតីសាមគ្គីភាពរបស់ប្រទេសជាមិត្ត អង្គការសហប្រជាជាតិ អង្គការដៃគូជាតិ និងអន្តរជាតិ ដែលបានចូលរួមជួយគ្នាក្នុងគ្រា

លំបាក ទាំងធនធានសម្ភារៈ ថវិកា បច្ចេកទេស យ៉ាងច្រើនលើសលប់ ក្នុងការដោះស្រាយបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋកម្ពុជាដែលកំពុងតែមានការខ្វះខាត និងកាត់បន្ថយភាពងគ្រោះជាថ្មីទៀត។

សូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ និងសាសនិកគ្រប់និកាយសាសនាទាំងអស់ ដែលមានឆន្ទៈចូលរួមក្នុងសកម្មភាពនានា ក្នុងគោលដៅលើកកម្ពស់សុវត្ថិភាពសង្គម និងសូមបន្តផ្សព្វផ្សាយ ដល់បព្វជិត និងសាវកជាសាសនិកជនរបស់ខ្លួនឱ្យបានជ្រួតជ្រាបកាន់តែច្បាស់អំពីអត្ថន័យ នៃទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា និងសារៈសំខាន់នៃការអប់រំបែបសាសនា សម្រាប់សេចក្តីថ្លៃថ្នូរ ភាពសុខដុមរមនា និងការរីកចម្រើន របស់យើងទាំងអស់គ្នា និងប្រទេសជាតិយើង។ សូមគោរពដឹងគុណ ចំពោះ សាសនាទាំងអស់ ជាពិសេសព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ដែលបានជួយចែករំលែកបន្ទុករបស់រាជរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហាសង្គម និងជាឃ្លាំងចំណេះដឹង មណ្ឌលវប្បធម៌ជាតិ និងជាជម្រកសម្រាប់ពេលមានអាសន្នដ៏កក់ក្ដៅ ដែលបច្ចុប្បន្នវត្តមួយចំនួន ត្រូវបានប្រើប្រាស់ជាជំរុំសម្រាប់ជនភៀសសឹកផងដែរ។

ជាទីបញ្ចប់ ទូលបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមលើកដៃបួងសួង ដល់គុណបុណ្យបារមី វត្ថុស័ក្តិសិទ្ធិក្នុងលោក សូមមេត្តាប្រទានស័ព្ទសាធុកាពរ ថ្វាយ **ព្រះករុណា សម្ដេចព្រះនរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** សូមស្ដេចគង់ជាម្លប់ ដ៏ត្រជាក់ដល់កូនចៅប្រជានុរាស្ត្រកម្ពុជា ប្រកបដោយព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន ព្រះប្រាជ្ញាភ្លឺថ្លាវាងវៃ អស់កាលដ៏យូរអង្វែងតទៅ។ សូមសម្ដេចព្រះមហាសង្ឃរាជាទាំងពីរគណៈ ព្រះរាជាគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ មានព្រះសុខភាពល្អ ដឹកនាំ ទ្រទ្រង់ព្រះពុទ្ធសាសនា ឱ្យបានរុងរឿងតរៀងទៅ។ សូមព្រះអឡោះ ព្រះយេស៊ូគ្រីស្ទ ប្រទានពរដល់សាសនិក ជាសាវកព្រះអង្គឱ្យទទួលបាននូវក្ដីសុខក្សេមក្សាន្ត និងសូម **សម្ដេច** ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ភ្ញៀវជាតិ និងអន្តរជាតិ ជាពិសេស យុទ្ធមិត្តដែលកំពុងឈរជើងនៅសមរភូមិមុខការពារអធិបតេយ្យភាពជាតិ នៅតាមបណ្ដោយព្រំដែនប្រកបដោយគ្រោះថ្នាក់ សូមបានជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺអាយុវណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរព្រះគុណ សូមអរគុណ!**